ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៧៥៤ ឧរថ.បល.ប្រក.

# ប្រកាស
## ស្ដីពី
## ការបង្កើតការិយាល័យស្ថិតិ និងព័ត៌មានវិទ្យា
## ចំណុះនាយកដ្ឋានឧស្សាហកម្មតូច និងសិប្បកម្ម

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៧០៤ / ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការប្រកាសអោយប្រើច្បាប់បង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញប្រកាសលេខ ២១៣ បល.ប្រក ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់នាយកដ្ឋានឧស្សាហកម្មតូច និងសិប្បកម្ម
- ពិនិត្យសំណូមពរការងារចាំបាច់របស់ក្រសួង

## សំរេច

ប្រការ១ : ត្រូវបានបង្កើត **ការិយាល័យស្ថិតិ និងព័ត៌មានវិទ្យា** បន្ថែមទៅក្នុងរចនាសម្ព័ន្ធរបស់នាយកដ្ឋានឧស្សាហកម្មតូច និងសិប្បកម្ម ដែលបង្កើតឡើងតាមប្រកាសលេខ ២១៣ បល.ប្រក ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ២០០០ ដែលមានតួនាទី និងភារកិច្ចដូចតទៅ :

<u>តួនាទី</u> :

ការិយាល័យស្ថិតិ និងព័ត៌មានវិទ្យា ជាអង្គភាពសេនាធិការជំនួយការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានលើការងារស្ថិតិ និងព័ត៌មានវិទ្យា ។

ភារកិច្ច ៖

- អង្កេត និងរៀបចំប្រមូលទិន្នន័យឧស្សាហកម្មតូច និងសិប្បកម្ម ។
- ធ្វើការវិភាគ និងវាយតម្លៃលើលទ្ធផលដែលទទួលបានពីឧស្សាហកម្មតូច និងសិប្បកម្ម ។
- រៀបចំបែបបទ និងនីតិវិធីទទួល និងផ្តល់ព័ត៌មានទាក់ទងទៅនឹងវិស័យឧស្សាហកម្មតូច និងសិប្បកម្ម ដល់អតិថិជន និងភាគីពាក់ព័ន្ធ ។
- រៀបចំព្រឹត្តិប័ត្រព័ត៌មានអំពីឧស្សាហកម្មតូច និងសិប្បកម្ម ។
- រៀបចំបញ្ចូលទិន្នន័យ និងព័ត៌មានក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។
- រៀបចំបោះពុម្ពឯកសារទាក់ទងនឹងការគ្រប់គ្រង និងការអភិវឌ្ឍន៍វិស័យឧស្សាហកម្មតូច និងសិប្បកម្ម បញ្ញត្តិបច្ចេកទេស ព្រឹត្តិប័ត្រ និងលិខិតផ្សេងៗរបស់នាយកដ្ឋាន ។
- រៀបចំតម្កល់ និងថែរក្សាសំណុំលិខិត ឯកសារពាក់ព័ន្ធនឹងការងារជំនាញ ។
- ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ អំពីលទ្ធផលការងារ ដែលអនុវត្តបាន ។

ប្រការ២ ៖ បទប្បញ្ញត្តិ និងសេចក្តីសំរេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៣ ៖ អគ្គាធិការ នៃអគ្គាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្ម នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ និង ហិរញ្ញវត្ថុ និង ប្រធាននាយកដ្ឋានឧស្សាហកម្មតូច និងសិប្បកម្ម មានភារៈកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួន តាមប្រកាសនេះ ។

ប្រការ៤ ៖ ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីកាលបរិច្ឆេទចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី២៦ ខែ កុម្ភៈ ឆ្នាំ២០០៧

រដ្ឋមន្ត្រី

ស៊ុយ សែម

កន្លែងទទួល ៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- រាជកិច្ច
- គ្រប់អគ្គនាយកដ្ឋាន
- គ្រប់នាយកដ្ឋាន
- គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលខេត្ត-ក្រុង
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

តារាងឧបសម្ព័ន្ធទី១
នៃប្រកាសលេខ ..................................
ចុះថ្ងៃទី ......... ខែ ................ ឆ្នាំ២០០៧

អង្គការលេខរបស់នាយកដ្ឋានឧស្សាហកម្មតូច និងសិប្បកម្ម




បានឃើញ
ភ្នំពេញ . ថ្ងៃទី ខែ ឆ្នាំ២០០៧
ឧ. រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
រដ្ឋលេខាធិការ
ញ៉ែក ច្រិន

បានពិនិត្យត្រឹមត្រូវ
ភ្នំពេញ . ថ្ងៃទី 12 ខែ កុម្ភៈ ឆ្នាំ២០០៧
អគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្ម
ខូន_សៅ

ភ្នំពេញ . ថ្ងៃទី 12 ខែ កុម្ភៈ ឆ្នាំ២០០៧
ប្រធាននាយកដ្ឋានឧស្សាហកម្មតូច និងសិប្បកម្ម